# ដំឡើង និងចុះឈ្មោះកម្មវិធី COVIDSafe app។



1. ទាញយក និងដំឡើងកម្មវិធី COVIDSafe app ពី **ហាង Apple App Store** ឬ **Google Play Store**។




2. នៅពេលបានដំឡើងហើយ សូមបើកកម្មវិធី អានអំពីរបៀបដែលយើងអាចបញ្ឈប់ការឆ្លងរាលដាល បន្ទាប់មកជ្រើសរើស ‘ខ្ញុំចង់ជួយ’ **I want to help**

   អានព័ត៌មានអំពីរបៀបដែល COVIDSafe ដំណើរការ

   បន្ទាប់មកជ្រើសរើស ‘បន្ទាប់ទៀត’ **Next**

   សម្រាប់ព័ត៌មានដែលបានបកប្រែស្តីពីរបៀបដែលកម្មវិធី COVIDSafe app ដំណើរការ សូមចូលមើល **www.health.gov.au/COVIDSafe-language**។




3. សូមអានព័ត៌មានស្តីពីការចុះឈ្មោះ និងឯកជនភាពបន្ទាប់មកជ្រើសរើស ‘បន្ត’ **Continue**

   អ្នកអាចអានគោលការណ៍ឯកជនភាពដែលបានបកប្រែនៅឯ **www.health.gov.au/covidsafe-privacy**



4. អ្នកត្រូវការផ្តល់ការយល់ព្រមសម្រាប់ការប្រមូលព័ត៌មានរបស់អ្នក។ សូមអានសេចក្តីថ្លែងអំពីការយល់ព្រមក្នុងការចុះឈ្មោះដូចខាងក្រោម។

ខ្ញុំយល់ព្រមចំពោះការប្រមូលរបស់ក្រសួងសុខាភិ បាលអូស្ត្រាលី៖

- ព័ត៌មានចុះឈ្មោះរបស់ខ្ញុំនឹងអនុញ្ញាតឱ្យមានការតាមដានទំនាក់ទំនងដោយមន្ត្រីសុខាភិបាលនៅតាមរដ្ឋ ឬ ដែនដី
- ព័ត៌មានទំនាក់ទំនងរបស់ខ្ញុំពីអ្នកប្រើប្រាស់ COVIDSafe ដទៃទៀតក្រោយពេលពួកគេធ្វើតេស្តឃើញ COVID-19 វិជ្ជមាន។

ប្រសិនបើអ្នកយល់ព្រមចំពោះការចុះឈ្មោះ និងព័ត៌មានទំនាក់ទំនងរបស់អ្នកដែលកំពុងត្រូវបានប្រមូល សូមជ្រើសរើស 'ខ្ញុំយល់ព្រម' I agree




5. ដើម្បីចុះឈ្មោះ សូមបញ្ចូល៖

- **ឈ្មោះរបស់អ្នក** (នេះអាចជារហស្សនាម) Full name
- **រង្វង់អាយុរបស់អ្នក** Age range (select)
- **លេខកូដប្រៃសណីយ៍របស់អ្នក** Postcode in Australia

ដោយមានការយល់ព្រមរបស់អ្នក នោះព័ត៌មានក្នុងការចុះឈ្មោះរបស់អ្នកនឹងត្រូវបានប្រើប្រាស់ដោយមន្ត្រីសុខាភិបាលនៅតាមរដ្ឋ និងដែនដី ដើម្បីទាក់ទងអ្នកប្រសិនបើអ្នកបានឆ្លងវីរុសកូរ៉ូណា (coronavirus)។




នៅពេលអ្នកបានបញ្ចូលព័ត៌មានលម្អិតអំពីការចុះឈ្មោះរបស់អ្នកហើយ សូមជ្រើសរើស "បន្ត" Continue

6. បញ្ចូល**លេខទូរសព្ទដៃរបស់អ្នក**បន្ទាប់មកជ្រើសរើស "ទទួលបាន PIN" Get PIN ដើម្បីផ្ទៀងផ្ទាត់លេខរបស់អ្នក។

មន្ត្រីសុខាភិបាលនឹងប្រើប្រាស់លេខទូរសព្ទដៃរបស់អ្នកដើម្បីទាក់ទងអ្នកប្រសិនបើ៖

- ធ្វើតេស្តឃើញវិជ្ជមាន ដើម្បីស្នើឱ្យអ្នកបង្ហោះព័ត៌មានរបស់អ្នក
- ដែលបានកំណត់ថាមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងអ្នកប្រើប្រាស់ COVIDSafe ផ្សេងទៀតដែលបានធ្វើតេស្តឃើញវិជ្ជមាន ដើម្បីផ្តល់ឱវាទដល់អ្នកអំពីអ្វីខ្លះដែលអ្នកត្រូវធ្វើ។

ប្រសិនបើអ្នកកំពុងជួយមិត្តភក្តិ ឬសាច់ញាតិដើម្បីទាញយកកម្មវិធី អ្នកនឹងត្រូវការទាញយកកម្មវិធីទៅដាក់លើទូរសព្ទរបស់ពួកគេ ហើយ បញ្ចូលទូរសព្ទរបស់ពួកគេចូលទៅក្នុងកម្មវិធី។




7. បន្ទាប់មកអ្នកនឹងទទួលសារជាអត្ថបទដែលមាន PIN 6 ខ្ទង់។

**បញ្ចូល PIN 6 ខ្ទង់** បន្ទាប់មកជ្រើសរើស "ផ្ទៀងផ្ទាត់" Verify

ប្រសិនបើអ្នកមិនទទួលបាន PIN ទេ សូមជ្រើសរើស "ផ្ញើ PIN ម្តងទៀត" Resend PIN

ប្រសិនបើទូរសព្ទដៃមិនត្រឹមត្រូវ សូមជ្រើសរើស "តើលេខទូរសព្ទដៃនេះខុសឬ?" Is this mobile number wrong?






**8.** ជ្រើសរើស ‘ដំណើរការបន្ត’ Proceed ដើម្បី**បើក Bluetooth® និងការជូនដំណឹង**។ ប្រសិនបើអ្នកជ្រើសរើសបើកការជូនដំណឹង នោះអ្នកនឹងទទួលការជូនដំណឹងប្រសិនបើ COVIDSafe មិនមានសកម្មភាព។

នៅពេលអ្នកបានចុះឈ្មោះជោគជ័យហើយ សូមជ្រើសរើស ‘បន្ត’ Continue




**សម្រាប់ Android** អ្នកនឹងត្រូវបានស្នើសុំឱ្យបិទការធ្វើឱ្យថ្មប្រសើរឡើង។ អ្នកអាចជ្រើសរើសដើម្បីផ្លាស់ប្តូរឈ្មោះឧបករណ៍របស់អ្នក។




**9.** នៅពេលអ្នកបានចុះឈ្មោះ និងត្រូវបានផ្តល់ការអនុញ្ញាតហើយ សូមរក្សាទុកឱ្យកម្មវិធី COVIDSafe app មានសកម្មភាព។ អ្នកអាចបញ្ជាក់រឿងនេះ ប្រសិនបើអ្នកមើលឃើញ ‘COVIDSafe មានសកម្មភាព’ COVIDSafe is active នៅលើអេក្រង់កម្មវិធីរបស់អ្នក។




**10.** ខណៈពេលមានសកម្មភាព COVIDSafe បន្តរក្សាការចំណាំដោយមានសុវត្ថិភាពនៃអ្នកប្រើប្រាស់ COVIDSafe ដទៃទៀតដែលបាននៅជិត។ ដោយមានការអនុញ្ញាតពីអ្នក នោះមន្ត្រីសុខាភិបាលអាចប្រើប្រាស់ព័ត៌មាននេះដើម្បីទាក់ទងមនុស្សនានា ប្រសិនបើអ្នកធ្វើតេស្តឃើញវិជ្ជមាន។

ព័ត៌មាននេះនៅតែស្ថិតនៅលើទូរសព្ទរបស់អ្នករយៈពេល 21 ថ្ងៃ ហើយមិនអាចចូលប្រើប្រាស់បានឡើយ ប្រសិនបើអ្នកមិនផ្តល់ការយល់ព្រមរបស់អ្នកទេ។

# ការបង្ហោះដោយស្ម័គ្រចិត្តនៃព័ត៌មានរបស់អ្នក ប្រសិនបើអ្នកធ្វើតេស្តឃើញវិជ្ជមាន

**11.** ប្រសិនបើអ្នកធ្វើតេស្តឃើញវិជ្ជមាន នោះមន្ត្រីសុខាភិបាលមកពីរដ្ឋ ឬដែនដីរបស់អ្នកនឹងទាក់ទងអ្នកដើម្បីសុំការអនុញ្ញាតពីអ្នកដើម្បីចូលប្រើប្រាស់ព័ត៌មានដែលបានប្រមូលដោយកម្មវិធី COVIDSafe app។

ជ្រើសរើស 'តើមន្ត្រីសុខាភិបាលបានទាក់ទងអ្នកហើយឬនៅ?' Has a health official contacted you? ពីកម្មវិធី។

បញ្ជាក់ថាមន្ត្រីសុខាភិបាលកំពុងសុំឱ្យអ្នកបង្ហោះព័ត៌មានរបស់អ្នក ដោយជ្រើសរើស 'បាទ/ចាស' Yes

ប្រសិនបើមន្ត្រីសុខាភិបាលមិនបានទាក់ទងអ្នកទេ សូមជ្រើសរើស 'ទេ' No










អ្នកត្រូវការយល់ព្រមចំពោះព័ត៌មានរបស់អ្នកដែលកំពុងត្រូវបានបង្ហោះ។ ប្រសិនបើអ្នកមិនយល់ព្រមទេ នោះព័ត៌មានទាក់ទងជិតស្និទ្ធរបស់អ្នកនឹងមិនត្រូវបានបង្ហោះទេ។ ប្រសិនបើអ្នកយល់ព្រម នោះព័ត៌មានទាក់ទងជិតស្និទ្ធរបស់អ្នកនឹងត្រូវបានបង្ហោះ និងត្រូវបានចែករំលែកជាមួយមន្ត្រីសុខាភិបាលនៅតាមរដ្ឋ ឬដែនដី ដើម្បីទាក់ទងមនុស្សដែលអាចបានឆ្លងវីរុស។

អ្នកអាចអានគោលការណ៍ឯកជនភាពអំពី COVIDSafe សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀតនៅឯ **www.health.gov.au/covidsafe-privacy**

ប្រសិនបើអ្នកយល់ព្រមបង្ហោះព័ត៌មានរបស់អ្នកដោយស្ម័គ្រចិត្ត សូមធីកលើប្រអប់ដែលនិយាយថា 'ខ្ញុំយល់ព្រម' I agree។ បន្ទាប់មកជ្រើសរើស 'បន្ត' Continue

**12.** មន្ត្រីសុខាភិបាលនឹងផ្ញើ PIN ដើម្បីបង្ហោះព័ត៌មានរបស់អ្នក។ បញ្ចូល PIN បន្ទាប់មកជ្រើសរើស 'បង្ហោះព័ត៌មានរបស់ខ្ញុំ' Upload my information







ជ្រើសរើស 'បន្ត' Continue ដើម្បីបំពេញដំណើរការ។ នៅពេលអ្នកបំពេញដំណើរការហើយ ព័ត៌មានត្រូវបានស្តុកទុកនៅក្នុងប្រព័ន្ធស្តុកទុកដែលមានសុវត្ថិភាពខ្ពស់។

មន្ត្រីសុខាភិបាលពីរដ្ឋ ឬដែនដីរបស់អ្នកនឹងចូលប្រើប្រាស់ព័ត៌មាននៅក្នុងកម្មវិធី ដើម្បីកំណត់អត្តសញ្ញាណមនុស្សដែលអ្នកបានទាក់ទងជិតស្និទ្ធ – ក្នុងចម្ងាយ 1.5 ម៉ែត្រអស់រយៈពេល 15 នាទី ឬច្រើនជាងនេះ។

ការនេះនឹងជួយមន្ត្រីសុខាភិបាលដើម្បីជូនដំណឹងឱ្យបានលឿនដល់មនុស្សដែលបាននៅជិតស្និទ្ធជាមួយ អ្នក ហើយដែលអាចឆ្លងវីរុសកូរ៉ូណា (coronavirus)។






13. មន្ត្រីសុខាភិបាលក៏អាចទាក់ទងអ្នក ប្រសិនបើអ្នកត្រូវបានកំណត់ថាបានមានទំនាក់ទំនងជិតស្និទ្ធជាមួយអ្នកប្រើប្រាស់កម្មវិធី COVIDSafe app ផ្សេងទៀត ដែលមានវីរុសកូរ៉ូណា (coronavirus)។ នៅក្នុងករណីនេះ មន្ត្រីសុខាភិបាលអាចផ្តល់ឱវាទថាអ្នកត្រូវការធ្វើតេស្តរកវីរុស។

14. អ្នកអាចលុបកម្មវិធី COVIDSafe app ពីទូរសព្ទរបស់អ្នកនៅពេលណាក៏បាន។ វានឹងលុបព័ត៌មានកម្មវិធី COVIDSafe app ទាំងអស់ពីទូរសព្ទរបស់អ្នក។ ព័ត៌មាននៅក្នុងប្រព័ន្ធស្តុកទុកព័ត៌មានដែលមាន សុវត្ថិភាពនឹងមិនត្រូវបានលុបចោលភ្លាមៗទេ។ វានឹងត្រូវបានបំផ្លាញចោលនៅពេលរដ្ឋមន្ត្រីក្រសួងសុខាភិបាលប្រកាសថាការឆ្លងរាលដាលបានចប់ហើយ។ ប្រសិនបើអ្នកចង់ឱ្យព័ត៌មានរបស់អ្នកត្រូវបានលុបចេញពីប្រព័ន្ធស្តុកទុកកាន់តែលឿន អ្នកអាចបំពេញទម្រង់បែបបទលុបទិន្នន័យ COVIDSafe របស់យើងនៅឯ **https://covidsafe-form.service.gov.au/**។

15. ព័ត៌មាន និងឯកជនភាពរបស់អ្នកត្រូវបានការពារ យ៉ាងតឹងរឹងដោយច្បាប់។ សូមអានគោលការណ៍ឯកជនភាពជាភាសារបស់អ្នកនៅឯ **www.health.gov.au/covidsafe-privacy**.

សម្រាប់ព័ត៌មាន និងជំនួយដទៃទៀត សូមទូរសព្ទទៅលេខ **1800 020 080**។